# ACCESS សំរាប់អ្នករៀនភាសាអង់គ្លេស (ELLs):

## សំណួរដែលបានសួរញឹកញាប់សម្រាប់មាតាបិតា / អាណាព្យាបាល

### តើ ACCESS សម្រាប់ ELLs ជាអ្វី?

ACCESS សម្រាប់ ELLs គឺជាតេស្តនៃជំនាញភាសាអង់គ្លេស។ វាត្រូវបានបង្កើតឡើងដោយអង្គការមិនរកប្រាក់ចំណេញដែលមានឈ្មោះថា WIDA ដែលមានមូលដ្ឋាននៅសាកលវិទ្យាល័យ Wisconsin។ ACCESS សម្រាប់ ELLs វាយតម្លៃលើការយល់ដឹងរបស់សិស្សនិងការប្រើប្រាស់ភាសាអង់គ្លេស ទាំងបួនជំនាញដូចជា ការស្តាប់ ការនិយាយ ការអាន និង ការសរសេរ។

### ហេតុអ្វីបានជាសិស្សធ្វើតេស្ត ACCESS សម្រាប់ ELLs?

នាមជាអ្នករៀនភាសាអង់គ្លេសមានន័យថាកូនសិស្សរបស់អ្នកកំពុងស្ថិតនៅក្នុងដំណើរការសិក្សាភាសាអង់គ្លេស។ ACCESS សម្រាប់ ELLs ជួយអ្នក និងកូនរបស់អ្នក និងគ្រូបង្រៀនរបស់កូនអ្នកដឹងពីរបៀបដែលជួយអោយសិស្សរៀនបានឆាប់រហ័ស និងវិធីសាស្រ្តនៃការគាំទ្រដែលមានប្រសិទ្ធភាពបំផុត។ ឧទាហរណ៍ប្រសិនបើសិស្សមានពិន្ទុល្អលើគ្រប់ជំនាញទាំងអស់ ប៉ុន្តែលើកលែងតែការសរសេរ នោះគ្រូបង្រៀននឹងត្រូវចំណាយពេលបន្ថែមទៅលើជំនាញនៃការសរសេរ។

ច្បាប់សិទ្ធិស៊ីវិលរបស់សហរដ្ឋអាមេរិក មានការពារអ្នករៀនភាសាអង់គ្លេស និងធានាដល់ពួកគេនូវការគាំទ្រដ៏មានប្រសិទ្ធភាពលើភាសាអង់គ្លេសនៅសាលារៀន។ ច្បាប់ស្តីពីការអប់រំរបស់សហព័ន្ធនិងរដ្ឋតម្រូវឱ្យមានការធ្វើតេស្តជំនាញភាសាអង់គ្លេសប្រចាំឆ្នាំព្រោះវាអាចជួយធានាថា តម្រូវការរបស់សិស្សត្រូវបានបំពេញ ដូច្នេះពួកគេអាចរៀនភាសាអង់គ្លេសបានលឿនតាមដែលអាចធ្វើទៅបាន។

### តើត្រូវចំណាយពេលប៉ុន្មានដើម្បីដល់កម្រិតស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាអង់គ្លេស?

ការមានភាពស្ទាត់ជំនាញក្នុងការសិក្សាភាសាអង់គ្លេសជាទូទៅត្រូវចំណាយពេលពី 4 ទៅ 7 ឆ្នាំ។ កុមារដែលចាប់ផ្តើមរៀនភាសាអង់គ្លេសនៅពេលពួកគេនៅក្មេងជាទូទៅរៀនលឿនជាងក្មេងធំៗ។ ប្រសិនបើកុមារមានការរំខានក្នុងការអប់រំឬមានពិការភាពក្នុងការរៀនសូត្រអាចត្រូវការពេលបន្ថែមបន្តិច។ ឪពុកម្តាយខ្លះជឿជាក់ថាការនិយាយតែភាសាអង់គ្លេសទៅកូននឹងអាចជួយឱ្យពួកគេរៀនឆាប់រហ័ស ប៉ុន្តែកុមារដែលចេះស្ទាត់ជំនាញលើភាសាកំណើតរបស់ពួកគេ អាចរៀនភាសា

អង់គ្លេសបានយ៉ាងងាយស្រួល និងជាទូទៅរៀនគ្រាន់បើនៅសាលារៀន។ ចំនួននិងគុណភាពនៃការគាំទ្រសិស្សទទួលបាននៅសាលារៀនក៏សំខាន់ដែរ។ សាកសួរសាលារបស់អ្នកអំពីរបៀបនៃការគាំទ្រដែលផ្តល់ដល់សិស្សរបស់អ្នក។ សាលារៀនពេញចិត្តចំពោះមតិយោបល់របស់ឪពុកម្តាយហើយនឹងធ្វើការជាមួយអ្នកដើម្បីអភិវឌ្ឍកម្មវិធីអប់រំដ៏ល្អបំផុតសម្រាប់កូនរបស់អ្នក។

ត្រូវប្រាកដថាសិស្សរបស់អ្នកយល់ថាគ្មានការធ្លាក់ ឬបរាជ័យនៅពេលមករៀននៅ ACCESS សម្រាប់ ELLs ។ ពិន្ទុរបស់សិស្សគឺជារង្វាស់កម្រិតរបស់គាត់ដើម្បីកំណត់ថាគាត់កំពុងឆ្ពោះទៅរកភាពស្ទាត់ជំនាញ។ វាមិនវាស់ស្ទង់ពីភាពឆ្លាតវៃរបស់សិស្សទេ។

**តើមានហានិភ័យអ្វីខ្លះលើការចូលរួម ACCESS សម្រាប់ ELLs?**

មិនមានហានិភ័យនោះទេ។ គ្រួសារសិស្សរៀនភាសាអង់គ្លេសប្រហែលជាបារម្ភថាភ្នាក់ងារសហព័ន្ធដូចជា ភ្នាក់ងារអន្តោប្រវេសន៍និងភ្នាក់ងារគយ (ICE) អាចចូលមើលកំណត់ត្រារបស់សិស្ស។ ជាទូទៅសាលារៀនត្រូវបានគេចាត់ទុកថាជា "តំបន់ប្រកាន់" ដូចជាព្រះវិហារឬមន្ទីរពេទ្យហើយ ICE មិនចាត់វិធានការប្រឆាំងនឹងជនអន្តោប្រវេសន៍គ្មានឯកសារស្របច្បាប់នៅឯសាលារៀនទេ។ ទោះជាយ៉ាងណាក៏ដោយដើម្បីអោយមានទំនុកចិត្ត អ្នកត្រូវចងចាំថាការធ្វើតេស្ត ACCESS ELL នេះអ្នកមិនតម្រូវអោយអ្នកប្រាប់សាលារៀនអំពីស្ថានភាពអន្តោប្រវេសន៍របស់កូនអ្នក ឬស្ថានភាពគ្រួសារទេ។ កុមារទាំងអស់ដែលរស់នៅសហរដ្ឋអាមេរិកមានសិទ្ធិចូលរៀនដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍។

សាលារៀនមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបំបាក់ទឹកចិត្តចំពោះការចុះឈ្មោះរបស់កុមារអន្តោប្រវេសន៍ដែលគ្មានឯកសារស្របច្បាប់នោះទេ ដោយសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ ឬ ដោយបដិសេធការចុះឈ្មោះរបស់កុមារដែលមានសំបុត្រកំណើតបរទេស ឬបដិសេធការចុះឈ្មោះចូលរៀនរបស់កុមារ ដែលមានឪពុកម្តាយបដិសេធមិនផ្តល់លេខសន្តិសុខសង្គមឬពូជសាសន៍ និងជាតិសាសន៍របស់ពួកគេ។

ប្រសិនបើអ្នកមានសំណួរអំពីការជូនដំណឹងនេះសូមទាក់ទងមក April Perkins អ្នកជំនាញ ESOL នៅលេខ (207)624-6627 ឬ april.perkins@maine.gov.